				_ _ _ – _ _ – _ _ _ _

▶ ព័ត៌មាននិយោជក *សុំព័ត៌មាននេះពីនិយោជករបស់លោកអ្នក។*

★ **កំណត់សម្គាល់សម្រាប់និយោជក**: ដើម្បីបំពេញពាក្យស្នើសុំ Covered California យើងខ្ញុំចាំបាច់ត្រូវដឹងអំពីការធានារ៉ាប់រងសុខភាព ដែលនិយោជិតរបស់លោកអ្នក ឬអ្នកនៅក្នុងបន្ទុករបស់ពួកគេអាចទទួលពីលោកអ្នក។ សូមបំពេញព័ត៌មានខាងក្រោម ទោះបីក្រុមហ៊ុនរបស់លោក អ្នកមិនផ្តល់ការធានារ៉ាប់រងសុខភាពក៏ដោយ។

ឈ្មោះនិយោជក		អត្តលេខនិយោជក (EIN)
		_ _ – _ _ _ _ _ _ _
អាសយដ្ឋាននិយោជក		លេខទូរស័ព្ទនិយោជក
ទីក្រុង	រដ្ឋ	លេខកូដតំបន់

តើយើងខ្ញុំអាចទំនាក់ទំនងអ្នកណាអំពីការធានារ៉ាប់រងសុខភាពនិយោជិត ចំពោះការងារនេះ?

លេខទូរសព្ទ	អាសយដ្ឋានអ៊ីម៉ែល

☐ យើងខ្ញុំមិនផ្តល់ការធានារ៉ាប់រងសុខភាពទេ។ ☐ និយោជិតនេះមិនគ្រប់លក្ខណៈសម្បត្តិទទួលការធានារ៉ាប់រង ក្រោមគម្រោងយើងខ្ញុំទេ។

☐ និយោជិតគ្រប់លក្ខណៈសម្បត្តិទទួលការធានារ៉ាប់សុខភាព ក្រោមគម្រោងរបស់យើងខ្ញុំ ដែលចាប់ផ្តើមនៅថ្ងៃ _____ *(កាលបរិច្ឆេទចាប់ផ្តើម)*។

តើគម្រោងសុខភាពតម្លៃទាបបំផុតសម្រាប់តែខ្លួនឯង ដែលនិយោជិតនេះ អាចចុះឈ្មោះនៅក្នុងការងារនេះ មានឈ្មោះអ្វី? ចូរពិនិត្យតែគម្រោងទាំងឡាយណា ដែលបំពេញតាម**បទដ្ឋានតម្លៃអប្បបរមា** * ដែលកំណត់ដោយច្បាប់សហព័ន្ធស្តីពីកិច្ចការពារអ្នកជំងឺ និងការថែទាំអាចមានលទ្ធភាពទិញបាន (Federal Patient Protection and Affordable Care Act) ឆ្នាំ 2010។ ប្រសិនបើលោកអ្នកមិនប្រាកដ សូមសាកសួរ ក្រុមហ៊ុនធានាសុខភាពរបស់លោកអ្នក។ ឈ្មោះ: _____ ☐ គ្មានគម្រោងដែលបំពេញតាម**បទដ្ឋានតម្លៃអប្បបរមា** *។	តើនិយោជិតត្រូវបង់បុព្វលាភធានារ៉ាប់រងប៉ុន្មានសម្រាប់តម្លៃទាបបំផុត? $ _____ ញឹកញាប់ប៉ុណ្ណា? ☐ ប្រចាំសប្តាហ៍ ☐ រៀងរាល់ពីរសប្តាហ៍ ☐ ពីរដងក្នុងមួយខែ ☐ ប្រចាំខែ ☐ ប្រចាំត្រីមាស ☐ ប្រចាំឆ្នាំ ផ្សេងៗ _____
តើលោកអ្នកនឹងមានការផ្លាស់ប្តូរអ្វីខ្លះសម្រាប់ឆ្នាំគម្រោងថ្មី (ប្រសិនបើបាន ដឹង)? ☐ យើងខ្ញុំមិនផ្តល់ការធានារ៉ាប់រងសុខភាពទេ ☐ យើងខ្ញុំនឹងចាប់ផ្តើមផ្តល់ការធានារ៉ាប់រងសុខភាពដល់និយោជិត ឬផ្លាស់ប្តូរ បុព្វលាភធានារ៉ាប់រងសម្រាប់គម្រោងចំណាយទាបបំផុតដល់និយោជិត ដែលបំពេញតាម**បទដ្ឋានតម្លៃអប្បបរមា** * ប៉ុណ្ណោះ។ (បុព្វលាភធានារ៉ាប់រង គួរឆ្លុះបញ្ចាំងអំពីការបញ្ចុះតម្លៃសម្រាប់កម្មវិធីថែទាំសុខភាព។)	តើនិយោជិតនឹងត្រូវបង់បុព្វលាភធានារ៉ាប់រងចំនួនប៉ុន្មានសម្រាប់គម្រោងធានារ៉ាប់រងនោះ? $ _____ ញឹកញាប់ប៉ុណ្ណា? ☐ ប្រចាំសប្តាហ៍ ☐ រៀងរាល់ពីរសប្តាហ៍ ☐ ពីរដងក្នុងមួយខែ ☐ ប្រចាំខែ ☐ ប្រចាំត្រីមាស ☐ ប្រចាំឆ្នាំ កាលបរិច្ឆេទផ្លាស់ប្តូរ _____

* **បទដ្ឋានតម្លៃអប្បបរមា** (**minimum value standard**) មានន័យថា គម្រោង មួយបង់ចំណាយយ៉ាងហោច 60%នៃការចំណាយសរុបនៃអត្ថ ប្រយោជន៍គម្រោង ដែលបានផ្តល់ទៅឲ្យនិយោជិត។ (ផ្នែក 36B(c)(2)(C) (ii) នៃច្បាប់ស្តីពីប្រាក់ចំណូលផ្ទៃ (Internal Revenue Code) ឆ្នាំ1986)។

ត្រូវការជំនួយឬ? ទូរស័ព្ទមក Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង 8ព្រឹកដល់ម៉ោង 8ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង 8ព្រឹកដល់ម៉ោង 6ល្ងាច ឬចូលទៅកាន់ **CoveredCA.com**.

ឯកសារភ្ជាប់ D: ចូរជ្រើសរើសគម្រោងសុខភាពធ្មេញកូនរបស់លោកអ្នក និង គម្រោងធានារ៉ាប់រងសុខភាពរបស់លោកអ្នក។

★ ប្រសិនបើលោកអ្នកចាំបាច់ត្រូវប្រាប់យើងខ្ញុំអំពីមនុស្សច្រើនជាងបួននាក់ដែលចង់ជ្រើសរើសគម្រោងសុខភាពធ្មេញកុមារឬគម្រោងសុខភាពរបស់លោកអ្នក **ចូរថតចម្លងទំព័រនេះ និងទំព័របន្ទាប់** ហើយត្រូវប្រាកដថា លោកអ្នកផ្ញើវាជាមួយនឹងពាក្យស្នើសុំរបស់លោកអ្នក។

ប្រសិនបើលោកអ្នកគិតថា លោកអ្នកគ្រប់លក្ខណៈសម្បត្តិទទួលជំនួយបង់បុព្វលាភធានារ៉ាប់រង ចូរសរសេរឈ្មោះ ឬ កម្រិតអត្ថប្រយោជន៍ធានារ៉ាប់រង (Metal tier) នៃគម្រោងសុខភាពធ្មេញកុមារ ឬគម្រោងធានារ៉ាប់រងសុខភាព ដែលលោកអ្នកចង់បានខាងក្រោម។ ដើម្បីសិក្សាបន្ថែមអំពីគម្រោងឯកជន ដែលផ្តល់ដោយ Covered California ចូលទស្សនាគេហទំព័រ **CoveredCA.com** ឬទូរស័ព្ទមកលេខ **1-800-906-8528** (TTY: 1-888-889-4500)។

ប្រសិនបើលោកអ្នកគិតថា លោកអ្នកគ្រប់លក្ខណៈសម្បត្តិទទួលសម្រាប់ Medi-Cal ចូរសរសេរឈ្មោះគម្រោងធានារ៉ាប់រងសុខភាព ដែលលោកអ្នក ចង់បានខាងក្រោម។ ដើម្បីសិក្សាបន្ថែមអំពីផែន Medi-Cal ដែលមាននៅក្នុងខោនធីរបស់លោកអ្នក ឬផ្លាស់ប្តូរគម្រោងរបស់លោកអ្នក នៅពេល លោកអ្នកចុះឈ្មោះភ្លាម សូមហៅទូរស័ព្ទមកកាន់ Health Care Options តាមរយៈទូរស័ព្ទលេខ **1-800-430-4263** (TTY: 1-800-430-7077) ឬចូលទៅកាន់គេហទំព័រ **healthcareoptions.dhcs.ca.gov** ។

ដើម្បីពិនិត្យថាតើលោកអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ Medi-Cal ឬជំនួយបុព្វលាភ សូមមើលឯកសារភ្ជាប់ F។

▶ ជ្រើសរើសគម្រោងសុខភាពធ្មេញកុមារ Covered California របស់លោកអ្នក *សម្រាប់កុមារអាយុ 18ឆ្នាំ ឬក្មេងជាងនេះតែប៉ុណ្ណោះ*

ឈ្មោះ *នាមខ្លួន នាមកណ្តាល នាមត្រកូល (ឧទាហរណ៍ Jr., Sr., III, IV)*	ឈ្មោះគម្រោងសុខភាពធ្មេញកុមារ	កម្រិតធានារ៉ាប់រង	ប្រភេទគម្រោងធានារ៉ាប់រង
កូនទី 1:		☐ ខ្ពស់ ☐ ទាប	☐ DEPO ☐ DPPO ☐ DHMO
កូនទី 2:		☐ ខ្ពស់ ☐ ទាប	☐ DEPO ☐ DPPO ☐ DHMO
កូនទី 3:		☐ ខ្ពស់ ☐ ទាប	☐ DEPO ☐ DPPO ☐ DHMO
កូនទី 4:		☐ ខ្ពស់ ☐ ទាប	☐ DEPO ☐ DPPO ☐ DHMO

DEPO–គឺជាអង្គភាពនៃអ្នកផ្តល់សេវាទន្តសាស្ត្រផ្តាច់មុខ។ DHMO–គឺជាអង្គភាពថែទាំសុខភាពមាត់ធ្មេញ។ DPPO–គឺជាអង្គភាពនៃអ្នកផ្តល់សេវាទន្តសាស្ត្រដែលមានការអនុញ្ញាត

▶ ជ្រើសរើសគម្រោងធានារ៉ាប់រងសុខភាពរបស់លោកអ្នក

គម្រោង Medi-Cal និង Covered California		<u>តែ</u>គម្រោង Covered California ប៉ុណ្ណោះ		
ឈ្មោះ *នាមខ្លួន នាមកណ្តាល នាមត្រកូល (ឧទាហរណ៍ Jr., Sr., III, IV)*	ឈ្មោះគម្រោងសុខភាព	កម្រិតអត្ថប្រយោជន៍ធានារ៉ាប់រង	លេខកម្រិតអត្ថប្រយោជន៍	ប្រភេទគម្រោង
បុគ្គលទី 1:		☐ Platinum ☐ Gold ☐ Silver ☐ Bronze ☐ គម្រោងធានារ៉ាប់រងអប្បបរមា		☐ EPO ☐ HMO ☐ HSA ☐ PPO
បុគ្គលទី 2:		☐ Platinum ☐ Gold ☐ Silver ☐ Bronze ☐ គម្រោងធានារ៉ាប់រងអប្បបរមា		☐ EPO ☐ HMO ☐ HSA ☐ PPO
បុគ្គលទី 3:		☐ Platinum ☐ Gold ☐ Silver ☐ Bronze ☐ គម្រោងធានារ៉ាប់រងអប្បបរមា		☐ EPO ☐ HMO ☐ HSA ☐ PPO
បុគ្គលទី 4:		☐ Platinum ☐ Gold ☐ Silver ☐ Bronze ☐ គម្រោងធានារ៉ាប់រងអប្បបរមា		☐ EPO ☐ HMO ☐ HSA ☐ PPO

EPO–អង្គភាពនៃអ្នកផ្តល់សេវាផ្តាច់មុខ។ HMO–អង្គភាពថែទាំសុខភាព។ HSA–គណនីប្រាក់សន្សំដើម្បីសុខភាព (ប្រភេទគម្រោងនេះអនុញ្ញាតឲ្យសមាជិកបើក និងដាក់រិភាគទានក្នុងគណនីសន្សំដើម្បីសុខភាព) PPO–អង្គភាពនៃអ្នកផ្តល់សេវាដែលមានការអនុញ្ញាត

ដើម្បីបំពេញការជ្រើសរើសយកគម្រោង គ្រប់បុគ្គលទាំងអស់ ដែលមានអាយុ 18 ឬចាស់ជាងនេះ ដែលកំពុងជ្រើសរើសគម្រោងធានារ៉ាប់រងសុខភាព ត្រូវតែយល់ព្រម និងចុះកិច្ចព្រមព្រៀងមជ្ឈត្តកម្ម នៅទំព័របន្ទាប់។

ឯកសារភ្ជាប់ D បន្តនៅទំព័របន្ទាប់

ត្រូវការជំនួយឬ? ទូរស័ព្ទមក Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង ៨ព្រឹកដល់ម៉ោង ៨ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង ៨ព្រឹកដល់ម៉ោង ៦ល្ងាច ឬចូលទៅកាន់ **CoveredCA.com**.

កិច្ចព្រមព្រៀងចងភ្ជាប់កាតព្វកិច្ចមជ្ឈត្តកម្ម

▶ សម្រាប់បុគ្គលម្នាក់ ដែលជ្រើសរើសគម្រោង Covered California:

ខ្ញុំយល់ថា គ្រប់ការចូលរួមគម្រោងសុខភាពទាំងអស់សុទ្ធតែមានវិធាន របស់វាក្នុងការដោះស្រាយវិវាទ ឬការទាមទារ រួមទាំង ប៉ុន្តែមិនកម្រិតត្រឹម ការទាមទារ ដែលខ្ញុំបាន អះអាង អ្នកនៅក្នុងបន្ទុករបស់ខ្ញុំ ដែលបានចុះឈ្មោះ អ្នកស្នងមរតក ឬតំណាងពេញសិទ្ធិចំពោះគម្រោងសុខភាព អ្នកផ្តល់សេវាថែទាំសុខភាពតាមកិច្ចសន្យា អ្នកគ្រប់គ្រង រដ្ឋបាល ឬភាគីពាក់ព័ន្ធផ្សេងទៀត អំពីសមាជិកភាពនៅក្នុងគម្រោងសុខភាព ការធានារ៉ាប់រង ឬការផ្តល់សេវា ឬសម្ភារៈផ្សេងៗ ការផ្តល់សេវាសុខភាពដោយមានការ ធ្វេសប្រហែស ឬការធ្វេសប្រហែសរបស់មន្ទីរពេទ្យ (ការទាមទារទៅលើការផ្តល់សេវាសុខភាព ដែលធ្វើឡើងមិនបានសមស្រប មិនចាំបាច់ គ្មានការអនុញ្ញាតធ្វេសប្រហែស ឬអសមត្ថភាព) ឬការទាមទារអំពីការទទួលខុសត្រូវនៅក្នុងបរិវេណ ឬកន្លែងផ្តល់សេវា។

ខ្ញុំយល់ថា ប្រសិនបើខ្ញុំជ្រើសរើសគម្រោងសុខភាពមួយ ដែលតម្រូវឲ្យចងកាតព្វកិច្ចមជ្ឈត្តកម្មដើម្បីដោះស្រាយវិវាទកើតឡើង ខ្ញុំយល់ព្រម ឬទទួលការចងភ្ជាប់កាតព្វកិច្ច មជ្ឈត្តកម្ម ដើម្បីដោះស្រាយវិវាទ ឬការទាមទារនានា (រឿងរំលងតែសំណុំរឿងក្តីទាមទារតូចតាចនៅតុលាការ និងការទាមទារដែលមិនបិតក្រោមកាតព្វកិច្ចមជ្ឈត្តកម្ម ក្រោមច្បាប់ពាក់ព័ន្ធ) និងលះបង់សិទ្ធិរបស់ខ្ញុំក្នុងការទទួលបានការជំនុំជម្រះដោយគណៈវិនិច្ឆ័យ និងមិនអាចធ្វើយរឿងក្តីនេះសម្រេចដោយតុលាការទេ លើកលែងតែមាន ច្បាប់ចែងអំពីការត្រួតពិនិត្យតាមផ្លូវច្បាប់នៃកិច្ចដំណើរការនីតិវិធីមជ្ឈត្តកម្ម។ ខ្ញុំយល់ថា ខចែងអំពីមជ្ឈត្តកម្មពេញលេញសម្រាប់ការចូលរួមគម្រោង សុខភាពនីមួយៗ មាននៅក្នុងឯកសារគម្រោងធានារ៉ាប់រងសុខភាព ប្រសិនបើគេមានឯកសារនោះ ដែលអាចរកបាននៅក្នុងគេហទំព័រ CoveredCA.com សម្រាប់ការពិនិត្យឡើងវិញ របស់ខ្ញុំ ឬ ខ្ញុំអាចហៅ ទូរស័ព្ទទៅកាន់ Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500) ដើម្បីទទួលបានព័ត៌មានបន្ថែម។

▶ សម្រាប់បុគ្គលនីមួយៗ ដែលជ្រើសរើសគម្រោងសុខភាព Kaiser Medi-Cal:

ការជូនដំណឹងអំពីកាតព្វកិច្ចមជ្ឈត្តកម្ម: ខ្ញុំបានអានការពិពណ៌នាអំពីគម្រោងៗ ខ្ញុំយល់ថា Kaiser តម្រូវឲ្យប្រើប្រាស់ការចងភ្ជាប់កាតព្វកិច្ចមជ្ឈត្តកម្មដែលអព្យាក្រឹត្យ ដើម្បីដោះស្រាយវិវាទមួយចំនួនៗ នេះរួមទាំងវិវាទអំពីថាតើការព្យាបាលសុខភាពត្រឹមត្រូវត្រូវបានផ្តល់ជូនឬយ៉ាងណា (ដែលគេហៅថាការព្យាបាលដោយការធ្វេស ប្រហែសឬគ្មានជំនាញច្បាស់លាស់) និងវិវាទផ្សេងទៀត ដែលទាក់ទងនឹងអត្ថប្រយោជន៍ ឬការផ្តល់សេវា រួមទាំងថាតើការផ្តល់សេវាសុខភាពធ្វើឡើង ដោយមិន ចាំបាច់ ឬដោយគ្មានការអនុញ្ញាត មិនសមស្រប ធ្វេសប្រហែស ឬអសមត្ថភាពឬយ៉ាងណា។ ប្រសិនបើខ្ញុំជ្រើសរើសយក Kaiser ជាគម្រោងសុខភាព Medi-Cal របស់ខ្ញុំនោះ ខ្ញុំបោះបង់សិទ្ធិរបស់ខ្ញុំតាមរដ្ឋធម្មនុញ្ញ ក្នុងការទទួលបានការជំនុំជម្រះដោយគណៈវិនិច្ឆ័យ ឬតុលាការចំពោះវិវាទទាំងនោះ។ ខ្ញុំក៏យល់ព្រមប្រើប្រាស់ការចង ភ្ជាប់កាតព្វកិច្ចមជ្ឈត្តកម្មដែលអព្យាក្រឹត្យ ដើម្បីដោះស្រាយវិវាទទាំងនោះផងដែរ។ ខ្ញុំមិនបោះបង់សិទ្ធិរបស់ខ្លួនក្នុងការទទួលបានសវនាការរបស់រដ្ឋអំពីបញ្ហាណាមួយ ដែលត្រូវអនុលោមតាមកិច្ចដំណើរការសវនាការរបស់រដ្ឋទេ។

▶ ហត្ថលេខាអ្នកចុះឈ្មោះសម្រាប់គ្រប់គម្រោង<u>ទាំងអស់</u>

ហត្ថលេខា**បុគ្គលទី1** ឬភាគីទទួលខុសត្រូវ ឬអ្នកតំណាងពេញសិទ្ធិ សម្រាប់បុគ្គលទី1 ប្រសិនបើមានអាយុយ៉ាងតិច 18ឆ្នាំ។ ▶	កាលបរិច្ឆេទ
ហត្ថលេខា**បុគ្គលទី2** ឬភាគីទទួលខុសត្រូវ ឬអ្នកតំណាងពេញសិទ្ធិ សម្រាប់បុគ្គលទី1 ប្រសិនបើមានអាយុយ៉ាងតិច 18ឆ្នាំ។ ▶	កាលបរិច្ឆេទ
ហត្ថលេខា**បុគ្គលទី3** ឬភាគីទទួលខុសត្រូវ ឬអ្នកតំណាងពេញសិទ្ធិ សម្រាប់បុគ្គលទី1 ប្រសិនបើមានអាយុយ៉ាងតិច 18ឆ្នាំ។ ▶	កាលបរិច្ឆេទ
ហត្ថលេខា**បុគ្គលទី4** ឬភាគីទទួលខុសត្រូវ ឬអ្នកតំណាងពេញសិទ្ធិ សម្រាប់បុគ្គលទី1 ប្រសិនបើមានអាយុយ៉ាងតិច 18ឆ្នាំ។ ▶	កាលបរិច្ឆេទ

សេចក្តីយោង *ចូរប្រើប្រាស់បញ្ជីទាំងនេះ ដើម្បី ឆ្លើយសំណួរក្នុងជំហានទី 2។*

ឋានភាពអន្តោប្រវេសន៍

ប្រើបញ្ជីនេះសម្រាប់ "ដាក់ពាក្យស្នើសុំការធានារ៉ាប់រងសុខភាព"

ប្រសិនបើលោកអ្នកមានឋានភាពអន្តោប្រវេសន៍មួយក្នុងចំណោមទាំងនេះ ***លោកអ្នកអាចគ្រប់លក្ខណៈសម្បត្តិសម្រាប់ការធានារ៉ាប់រងសុខភាព។***

- អ្នករស់នៅអចិន្ត្រៃយ៍ស្របច្បាប់ (LPR) ឬអ្នកមានបណ្ណសម្គាល់សិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ (Greencard Holder)
- អ្នករស់នៅបណ្តោះអាសន្នស្របច្បាប់ (LTR)
- អ្នកសុំសិទ្ធិជ្រកកោន
- ជនភៀសខ្លួន
- ជនជាតិគុយបា/ហៃទីដែលទទួលស្គាល់ដោយអាជ្ញាធរអន្តោប្រវេសន៍សហរដ្ឋអាមេរិក
- បានទទួលសិទ្ធិឲ្យចូលសហរដ្ឋអាមេរិក
- អ្នកចូលសញ្ជាតិជាប់លក្ខខណ្ឌ ដែលបានអនុញ្ញាតមុនឆ្នាំ1980
- ប្តី/ប្រពន្ធ កូន ឬឪពុក/ម្តាយ ដែលរងការវាយដំ
- ជនរងគ្រោះពីការរត់ពន្ធ និងប្តី/ប្រពន្ធ កូន បង/ប្អូន ឬឪពុក/ម្តាយរបស់ជននោះ
- បុគ្គលដែលមានឋានភាពមិនមែនជាជនអន្តោប្រវេសន៍ (រួមមាន កម្មករ និងសិស្ស ដែលស្នាក់នៅដោយមានទិដ្ឋាការ និងពលរដ្ឋ Micronesia ពលរដ្ឋ Marshall Islands និង Palau)
- ឋានភាពស្ថិតក្រោមកិច្ចការពារបណ្តោះអាសន្ន (TPS) ឬ អ្នកដាក់ពាក្យស្នើសុំឋានភាពដែលបានកិច្ចការពារបណ្តោះអាសន្ន (TPS)
- ការអនុគ្រោះលើការចាកចេញដោយបង្ខំ (Deferred Enforced Departure, DED)
- ឋានភាពអនុគ្រោះឲ្យស្នាក់នៅបណ្តោះអាសន្ន (Deferred action status)
  សម្គាល់ ៖ ប្រសិនបើលោកអ្នកជាបុគ្គលដែលមានឋានភាពអនុគ្រោះឲ្យស្នាក់នៅបណ្តោះអាសន្នក្រោមការអនុគ្រោះសម្រាប់ដំណើរការមកដល់របស់កុមារ (DACA) នៃក្រសួងសន្តិសុខជាតិ នោះលោកអ្នកមិនត្រូវបានចាត់ទុកថាមានវត្តមានស្របច្បាប់នោះទេ។
- បានទទួលការព្យួរទុកការនិរទេស ឬការព្យួរទុកការបណ្តេញចេញក្រោមច្បាប់អន្តោប្រវេសន៍ ឬក្រោមអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (Convention against Torture, CAT)
- អ្នកដាក់ពាក្យសុំការដកហូតការនិរទេសខ្លួន ឬដកហូតការបណ្តេញចេញក្រោមច្បាប់អន្តោប្រវេសន៍ ឬក្រោមអនុសញ្ញាប្រឆាំងនឹងទារុណកម្ម (CAT)
- អ្នកដាក់ពាក្យសុំឋានភាពអន្តោប្រវេសន៍អនីតិជនពិសេស
- អ្នកដាក់ពាក្យសុំការកែសម្រួលឋានភាព LPR ជាមួយនឹងបដ្ឋនាលិខិតទិដ្ឋាការដែលបានអនុញ្ញាត
- អ្នកដាក់ពាក្យសុំសិទ្ធិជ្រកកោន
- អ្នកដាក់ពាក្យសុំចុះឈ្មោះជាមួយនឹងឯកសារអនុញ្ញាតការងារ (EAD)
- ដីកាត្រួតពិនិត្យ (ជាមួយ EAD)
- អ្នកដាក់ពាក្យសុំលុបចោលការដកចេញ ឬព្យួរការនិរទេស (ជាមួយ EAD)

ប្រសិនបើឋានភាពអន្តោប្រវេសន៍លោកអ្នកមិនបានរៀបរាប់ខាងលើ លោកអ្នកនៅតែអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការធានារ៉ាប់រងសុខភាព ហើយនៅតែអាចដាក់ពាក្យបាន។

បម្រើការងារឲ្យខ្លួនឯង

ប្រើប្រាស់បញ្ជីនេះ សម្រាប់ "តើលោកអ្នកធ្វើការងារខ្លួនឯងឬទេ?"

លោកអ្នកអាចដកចំណូលទាំងនេះ ចេញពីចំណូលសរុបរបស់លោកអ្នក ដើម្បីស្វែងរកពីចំណូលសុទ្ធបានពីការធ្វើការងារឲ្យខ្លួនឯង។ មើល "សេចក្តីណែនាំសម្រាប់តារាង C" នៅ **irs.gov** សម្រាប់ព័ត៌មានបន្ថែម។

- ចំណាយលើរថយន្ត និងរថយន្តដឹកទំនិញ (ការធ្វើដំណើរនៅពេលធ្វើការ មិនមែនការធ្វើដំណើរពីផ្ទះ ទៅកន្លែងធ្វើការឡើយ)
- ការជួលៈ
- ប្រាក់ខែនិយោជិត និងអត្ថប្រយោជន៍បន្ទាប់បន្សំ
- ទ្រព្យសម្បត្តិ បំណុល ឬការធានារ៉ាប់រងលើការអាក់ខានពាណិជ្ជកម្ម
- ការប្រាក់ (ឧទាហរណ៍ ការប្រាក់អ៊ីប៉ូតែកដែលត្រូវបង់ឲ្យធនាគារ)
- សេវាផ្នែកច្បាប់ និងអាជីព
- ការជួលសេវា និងអចលនទ្រព្យពាណិជ្ជកម្ម
- កម្រៃជើងសារ អាករ អាជ្ញាប័ណ្ណ និងឈ្នួល
- ការផ្សាយពាណិជ្ជកម្ម
- ការងារជាប់កិច្ចសន្យា
- ការជួសជុល និងថែទាំ
- ្ អាហារ និងការធ្វើដំណើរពាណិជ្ជកម្មជាក់លាក់មួយចំនួ ន

ឧទាហរណ៍ស្តីពីចំណូលផ្សេងទៀត

ប្រើប្រាស់បញ្ជីនេះ សម្រាប់ "តើលោកអ្នកមានចំណូលផ្សេងទៀតដែរឬទេ?"

- អត្ថប្រយោជន៍និកម្មភាព
- អត្ថប្រយោជន៍សន្តិសុខសង្គម
- ចំណូលសោធននិវត្តន៍
- ចំណូលពីការជួល ឬកម្រៃអ្នកនិពន្ធ
- សោធនអាហារកិច្ច
- ចំណូលពីការវិនិយោគ
- ចំណេញជាមូលធន
- ចំណូលពីកសិកម្ម ឬនេសាទ
- បំណុលដែលបានលុបចោល
- សេចក្តីសម្រេចរបស់តុលាការ
- កម្រៃសមាជិកគណៈវិនិច្ឆ័យ
- ផ្សេងៗ

ប្រាក់ត្រូវកាត់ចេញ

ប្រើប្រាស់បញ្ជីនេះ សម្រាប់ "តើលោកអ្នកមានប្រាក់ត្រូវកាត់ចេញដែរឬទេ?"

- ចំណាយលើការធ្វើការងារឲ្យខ្លួនឯងមួយចំនួន
- ប្រាក់ត្រូវកាត់ចេញជាការប្រាក់នៃកម្ចីសម្រាប់ការសិក្សា
- ថ្លៃឈ្នួល និងសោហ៊ុយ
- ចំណាយអ្នកអប់រ
- វិភាគទាន IRA
- ចំណាយក្នុងការផ្លាស់ប្តូរទីលំនៅ
- ការពិន័យលើការប្រាក់សន្សំមុនកាលកំណត់
- ប្រាក់កាត់ចេញពីគណនីសន្សំដើម្បីសុខភាព
- សោធនអាហារកិច្ចដែលបានបង់
- ប្រាក់កាត់ចេញពីសកម្មភាពផលិតកម្មក្នុងស្រុក
- ចំណាយខាងពាណិជ្ជកម្មជាក់លាក់មួយចំនួននៃទាហានបម្រុង វិចិត្រការសម្តែង និងមន្ត្រីរដ្ឋាភិបាលស៊ីវិលកម្រៃសេវា

ត្រូវការជំនួយឬ? ទូរស័ព្ទមក Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង ៨ព្រឹកដល់ម៉ោង ៨ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង ៨ព្រឹកដល់ម៉ោង ៦ល្ងាច ឬចូលទៅកាន់ **CoveredCA.com**.

ឯកសារភ្ជាប់ F: គោលការណ៍ណែនាំពីភាពក្រីក្រសហព័ន្ធ

▶ ប៉ាន់ប្រមាណពីប្រភេទនៃការធានារ៉ាប់រងសុខភាពដែលលោកអ្នកអាចនឹងមានសិទ្ធិទទួលបាននៅក្នុងឆ្នាំ 2014។

ចំនួនសមាជិកនៅក្នុងគ្រួសារ	ប្រសិនបើចំណូលគ្រួសារប្រចាំឆ្នាំរបស់លោកអ្នកទាបជាង ៖	ប្រសិនបើចំណូលគ្រួសារប្រចាំឆ្នាំរបស់លោកអ្នកនៅចន្លោះពី ៖
1	$15,860*	$15,860 – $45,960
2	$21,400	$21,400 – $62,040
3	$26,950	$26,950 – $78,120
4	$32,500	$32,500 – $94,200
5	$38,050	$38,050 – $110,280
	⬇	⬇
	លោកអ្នកអាចមានសិទ្ធិទទួលបាន Medi-Cal។	**លោកអ្នកអាចមានសិទ្ធិទទួលបានការធានារ៉ាប់រងសុខភាពជាមួយនឹងជំនួយផ្នែកហិរញ្ញវត្ថុតាមរយៈ Covered California ។**

** បរិមាណចំណូលគ្រួសារប្រចាំឆ្នាំទាំងនេះ គឺគ្រាន់តែជាការប្រហាក់ប្រហែលប៉ុណ្ណោះ និងផ្អែកលើទិន្នន័យចំណូលឆ្នាំ 2013។*

ប្រសិនបើលោកអ្នកមានការធានារ៉ាប់រងក្នុងតម្លៃសមស្របពីនិយោជក ឬកម្មវិធីរដ្ឋាភិបាលដូចជា Medicare ឬ Medicaid នោះ លោកអ្នកនឹងមិនអាចមានសិទ្ធិទទួលបានគម្រោងធានារ៉ាប់រងសុខភាព Covered California ឡើយ។

★ ប្រសិនបើលោកអ្នកមានកូន ឬមានផ្ទៃពោះ លោកអ្នកអាចមានប្រាក់ ចំណូលកាន់តែខ្ពស់ ហើយនៅតែអាចគ្រប់លក្ខណៈសម្បត្តិទទួលការ ធានារ៉ាប់រងដោយឥតគិតថ្លៃ ឬតម្លៃទាប តាមរយៈ Medi-Cal ឬ AIM។ ប្រសិនបើលោកអ្នកមានផ្ទៃពោះ លោកអ្នកនិងទារក ដែលនឹងកើតមក របស់លោកអ្នក (ទារក) នឹងត្រូវរាប់ជាបុគ្គលដោយឡែក ដើម្បីបានគ្រប់លក្ខណៈសម្បត្តិទទួល Medi-Cal និងជាបុគ្គលម្នាក់ទទួលបានជំនួយ ហិរញ្ញវត្ថុ តាមរយៈ Covered California។

សំណួរជាទូទៅ (FAQ)

ទទួលជំនួយតាមរយ: Covered California

1. តើ Covered California ជាអ្វី ?

Covered California គឺជាទីផ្សារថ្មី ដែលអាចឲ្យបុគ្គលទាំងឡាយ និង ក្រុមគ្រួសារនានាមានលទ្ធផលភាពទទួលបានការធានារ៉ាប់រងសុខភាព ដោយឥតគិតថ្លៃ ឬចំណាយទាប តាមរយ: Medi-Cal ឬទទួលបានជំនួយ ក្នុងការបង់ការធានារ៉ាប់រងសុខភាពឯកជន ដែលរកបានតាមរយ: Covered California។

យើងខ្ញុំមានគោលបំណងធ្វើឲ្យពលរដ្ឋកាលីហ្វ័រញ៉ា អាចមានលទ្ធភាពទទួលបាន ការធានារ៉ាប់រងសុខភាពដោយសមរម្យនិងសាមញ្ញ។ Covered California គឺជាដៃគូមួយនៃ កម្មវិធីផ្លាស់ប្តូរអត្ថប្រយោជន៍សុខភាពនៃរដ្ឋកាលីហ្វ័រញ៉ា (California Health Benefit Exchange) និងក្រសួងផ្តល់សេវាថែទាំសុខភាព រដ្ឋកាលីហ្វ័រញ៉ា (California Department of Health Care Services។

2. តើ Medi-Cal គឺជាអ្វី ?

Medi-Cal គឺជាកម្មវិធី Medicaid សហព័ន្ធដែលបានកែប្រែថ្មីរបស់ California។ វាជាការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬមានតម្លៃទាបសម្រាប់ពលរដ្ឋក្នុងរដ្ឋ California ដែលមានសិទ្ធិទទួលបាន។

3. តើកម្មវិធី Access for Infants and Mothers (AIM) គឺជាអ្វី ?

AIM គឺជាកម្មវិធីធានារ៉ាប់រងសុខភាពដែលមានតម្លៃទាបសម្រាប់ស្ត្រីមានផ្ទៃពោះ ដែលមិនមានការធានារ៉ាប់រងសុខភាព និងមានចំណូលខ្ពស់ពេកសម្រាប់ Medi-Cal ដោយឥតគិតថ្លៃ។ AIM ក៏អាចមានសម្រាប់ស្ត្រីដែលមានគម្រោងធានារ៉ាប់រងសុខភាពឯកជនជាមួយនឹងប្រាក់ត្រូវកាត់ចេញ ឬការបង់ប្រាក់សម្រាប់តែពេលសម្រាលដែលច្រើនជាង 500$។

4. តើ Covered California អាចជួយខ្ញុំដោយរបៀបណា ?

Covered California អាចជួយលោកអ្នកក្នុងការជ្រើសរើសគម្រោងធានារ៉ាប់រងឯកជនដែលបំពេញតាមតម្រូវការផ្ទែកសុខភាព និងថវិកាលោកអ្នក។ យើងខ្ញុំផ្តល់គម្រោងសុខភាពមួយចំនួនដែលល្បីល្បាញបំផុតនៅក្នុងរដ្ឋ និងគម្រោងក្នុងស្រុក ឬក្នុងតំបន់មួយចំនួនទៀតផងដែរ។

យើងខ្ញុំអាចពន្យល់ពីចំណាយ និងអត្ថប្រយោជន៍នៃគម្រោងធានារ៉ាប់រងសុខភាពបានច្បាស់លាស់ដើម្បីឲ្យលោកអ្នកអាចប្រៀបធៀបជម្រើសផ្សេងទៀតដែលមានសម្រាប់លោកអ្នក។ លោកអ្នកនឹងដឹងច្បាស់ពីអ្វីដែលខ្លួនកំពុងទទួលបាន និងតម្លៃដែលលោកអ្នកត្រូវបង់មុនពេលជ្រើសរើសយកគម្រោងរបស់លោកអ្នក។

5. តើខ្ញុំអាចទទួលបានការធានារ៉ាប់រងសុខភាពឬទេប្រសិនបើចំណូលខ្ញុំខ្ពស់ពេក ?

បាន អ្នកស្រុកនៃរដ្ឋកាលីហ្វ័រញ៉ា ដែលគ្រប់លក្ខណ:សម្បត្តិអាចទិញការធានារ៉ាប់រងសុខភាពឯកជនបាន តាមរយ:Covered California ដោយមិនគិតអំពី ប្រាក់ចំណូល។ យើងខ្ញុំប្រើប្រាស់ប្រាក់ចំណូលរបស់លោកអ្នក ដើម្បីជួយយើង ខ្ញុំក្នុងការរកការធានារ៉ាប់រងណា ដែលក្រុមគ្រួសាររបស់លោកអ្នកអាចមាន លទ្ធភាពសាកសមបំផុត។

6. តើការធានារ៉ាប់រងសុខភាពអ្វីត្រូវបានផ្តល់ជូនតាមរយ: Covered California ?

លោកអ្នកនឹងមានគម្រោងសុខភាពផ្សេងៗសម្រាប់ជ្រើសរើស។ ក្រុមហ៊ុនធានារ៉ាប់រងសុខភាព**មិនអាចបដិសេធផ្តល់ការធានារ៉ាប់រងដល់លោកអ្នក**ដោយសារតែលោកអ្នកធ្លាប់ឈឺពីមុន ឬមិនអាចទទួលបានការធានារ៉ាប់រង។

Covered California ផ្តល់គម្រោងធានារ៉ាប់រងសុខភាពឯកជនបួនក្រុមដូចជា៖ Platinum, Gold, Silver និង Bronze បូកនឹងគម្រោងធានារ៉ាប់រងអប្បបរមា។

ក្រុមនីមួយៗផ្តល់នូវកម្រិតធានារ៉ាប់រងខុសៗគ្នា ពីខ្ពស់ទៅទាប។ គម្រោងធានារ៉ាប់រងសុខភាពដែលរ៉ាប់រងលើចំណាយវេជ្ជសាស្ត្របន្ថែមរបស់លោកអ្នកនឹងមានបុព្វលាភខ្ពស់ជាង ប៉ុន្តែអាចឲ្យលោកអ្នកបង់តិចជាងនៅពេលដែលលោកអ្នកទទួលបានការថែទាំបែបវេជ្ជសាស្ត្រ។

គម្រោង Platinum មានបុព្វលាភខ្ពស់បំផុត ប៉ុន្តែវាបង់ប្រហែលជា 90%នៃចំណាយក្នុងការថែទាំសុខភាពរបស់លោកអ្នក។ គម្រោង Gold បង់ប្រហែលជា 80% និងគម្រោង Silver បង់ប្រហែលជា 70% នៃចំណាយក្នុងការថែទាំសុខភាពរបស់លោកអ្នក។ គម្រោង Bronze មានបុព្វលាភទាបបំផុត ប៉ុន្តែបង់ប្រហែលជា 60% នៃចំណាយលើសុខភាពដែលធានារ៉ាប់រង។ ដើម្បីស្វែងយល់បន្ថែមអំពីកញ្ចប់អត្ថប្រយោជន៍ពេញលេញដែលមានសូមចលទៅកាន់ **CoveredCA.com** ហើយពិនិត្យឡើងវិញលើឯកសារគម្រោងដូចជា ភស្តុតាងធានារ៉ាប់រងរបស់គម្រោង ឬគោលនយោបាយធានារ៉ាប់រងរបស់គម្រោង។ ឬទូរស័ព្ទមកកាន់យើងខ្ញុំតាមរយ:លេខ **1-800-906-8528** (TTY: 1-888-889-4500)។

ប្រសិនបើលោកអ្នកគ្រប់លក្ខណ:សម្បត្តិទទួល Medi-Cal ការធានារ៉ាប់រងនិងការចំណាយ មានលក្ខណ:ខុសគ្នា និងអាចមិនគិតថ្លៃសម្រាប់លោកអ្នក។

7. តើខ្ញុំអាចទទួលបានការធានារ៉ាប់រងសុខភាពតាមរយ: Covered California ដែរឬទេ ?

ពលរដ្ឋ California គ្រប់រូបអាចទទួលបានការធានារ៉ាប់រងសុខភាពតាមរយ: Covered California ប្រសិនបើពួកគេគឺជាអ្នករស់នៅក្នុងរដ្ឋ ហើយបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្សេងទៀត។

អ្នកដាក់ពាក្យអាចមានលក្ខណ:សម្បត្តិគ្រប់គ្រាន់សម្រាប់គម្រោងសុខភាពដោយឥតគិតថ្លៃ ឬមានតម្លៃទាប ឬសម្រាប់ជំនួយហិរញ្ញវត្ថុដែលអាចបន្ថយចំណាយបុព្វលាភ និងថ្លៃចំណាយ។ បរិមាណនៃជំនួយហិរញ្ញវត្ថុគឺ អាស្រ័យលើទំហំគ្រួសារ និងចំណូលគ្រួសារ។ អ្នកដាក់ពាក្យមានលក្ខណ:សម្បត្តិគ្រប់គ្រាន់ប្រសិនបើចំណូលពួកគេបំពេញតាមចំនួនកំណត់នៃចំណូល។

8. តើវាមានតម្លៃប៉ុន្មាន ?

តម្លៃរបស់វាអាស្រ័យលើកម្មវិធីធានារ៉ាប់រងសុខភាពអ្វី និងជំនួយហិរញ្ញវត្ថុអ្វី ដែលលោកអ្នកគ្រប់លក្ខណ:សម្បត្តិនឹងទទួល ព្រមទាំងគម្រោងណាមួយ ដែលលោកអ្នកជ្រើសរើស។ លោកអ្នកអាចប្រើប្រាស់ម៉ាស៊ីនគិតលេខលើតម្លៃរបស់វាបាន តាមរយ: **CoveredCA.com** ដើម្បីរកមើលតម្លៃ និងពីនិត្យមើលថាតើលោកអ្នកគ្រប់លក្ខណ:សម្បត្តិទទួលជំនួយសម្រាប់បង់ការធានារ៉ាប់រងឬយ៉ាងណា។

សំណួរជាទូទៅ បន្តនៅទំព័របន្ទាប់

ត្រូវការជំនួយឬ ? ទូរស័ព្ទមក Covered California តាមរយ:លេខ **1-800-906-8528** (TTY: 1-888-889-4500)។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង 8ព្រឹកដល់ម៉ោង 8ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង 8ព្រឹកដល់ម៉ោង 6ល្ងាច ឬចូលទៅកាន់ **CoveredCA.com**.

CCFRM604 (11/13) KH

ទទួលជំនួយតាមរយៈ Covered California *(បន្ត)*

9. តើខ្ញុំគួរតែបញ្ចូលប្រាក់បង់បុព្វលាភធានារ៉ាប់រងលើកដំបូងរបស់ខ្ញុំជាមួយ នឹងពាក្យស្នើសុំនេះទេ?

ទេ ចូរកុំផ្ញើប្រាក់បង់បុព្វលាភធានារ៉ាប់រងលើកដំបូងរបស់លោកអ្នកជាមួយ នឹងពាក្យ ស្នើសុំនេះ។ គម្រោងធានារ៉ាប់រងរបស់លោកអ្នកនឹងផ្ញើវិក្កយបត្រឲ្យលោកអ្នក សម្រាប់ទឹកប្រាក់ដែលលោកអ្នកជំពាក់។

10. តើខ្ញុំដាក់ពាក្យស្នើសុំតាមវិធីណា?

លោកអ្នកអាចដាក់ពាក្យស្នើសុំការធានារ៉ាប់រងសុខភាព តាមរយៈ Covered California តាមមធ្យោបាយដូចខាងក្រោម៖

- **វែបសាយ**: ចូលទៅកាន់ **CoveredCA.com**។ យើងខ្ញុំមានផ្តល់ជូននូវព័ត៌មានអំពីគម្រោងធានារ៉ាប់រងនីមួយៗ ដែលបានពន្យល់ជាពាក្យពេចន៍ងាយយល់ និងច្បាស់លាស់។
- **តាមទូរស័ព្ទ**: ទូរស័ព្ទមក Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង ៨ព្រឹកដល់ម៉ោង ៨ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង ៨ព្រឹកដល់ម៉ោង ៦ល្ងាច។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ!
- **តាមទូរសារ**: ផ្ញើពាក្យសុំរបស់លោកអ្នកតាមទូរសារលេខ **1-888-329-3700**។
- **តាមរយៈសំបុត្រ**: ផ្ញើពាក្យសុំរបស់ Covered California តាមរយៈសំបុត្រមកកាន់

  Covered California
  P.O. Box 989725
  West Sacramento, CA 95798-9725
- **មកជួបផ្ទាល់**: យើងបានបណ្តុះបណ្តាល អ្នកផ្តល់ប្រឹក្សាអំពីការចុះឈ្មោះដែលមានការទទួលស្គាល់ (Certified Enrollment Counselors) និងភ្នាក់ងារ ធានារ៉ាប់រងដែលមានការទទួលស្គាល់ (Certified Insurance Agents) ដែលអាចជួយលោកអ្នកបាន។ ឬលោកអ្នកអាចមកកាន់ការិយាល័យសេវាសង្គម របស់ខោនធីលោកអ្នក។ ជំនួយនេះគឺឥតគិតថ្លៃ! សម្រាប់បញ្ជីទីកន្លែងដែលនៅជិតកន្លែងលោកអ្នករស់នៅ ឬធ្វើការ សូមចូលទៅកាន់ **CoveredCA.com** ឬទូរសព្ទមកលេខ **1-800-906-8528** (TTY: 1-888-889-4500)។

11. ខ្ញុំកំពុងចុះឈ្មោះនៅក្នុង Medi-Cal។ តើខ្ញុំអាចទទួលបានការធានារ៉ាប់រងសុខភាពតាមរយៈ Covered California ដែរឬទេ?

ប្រសិនបើប្រាក់ចំណូលលោកអ្នកមានការប្រែប្រួលនៅក្នុងអំឡុងឆ្នាំ ឬក្នុង ពេលបន្តសុពលភាពសេវាប្រចាំឆ្នាំរបស់លោកអ្នកជាថ្មីទៀត លោកអ្នកអាចគ្រប់លក្ខណៈសម្បត្តិទទួលការធានារ៉ាប់រងសុខភាពផ្សេងទៀត និងជំនួយបុព្វលាភធានារ៉ាប់រងតាមរយៈ Covered California។

12. តើធ្វើដូចម្តេចប្រសិនបើខ្ញុំមានការធានារ៉ាប់រងរួចហើយ?

ប្រសិនបើលោកអ្នកមានការធានារ៉ាប់រងសុខភាពដែលមានតម្លៃសមរម្យរួចហើយ ពីនិយោជករបស់លោកអ្នកនោះ លោកអ្នកមិនចាំបាច់ធ្វើអ្វីទេ។ ប៉ុន្តែលោកអ្នកនៅតែអាចដាក់ពាក្យស្នើសុំដើម្បីរកមើលថាតើលោកអ្នក ឬសមាជិកគ្រួសាររបស់លោកអ្នកគ្រប់លក្ខណៈសម្បត្តិទទួលការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ ឬក្នុងតម្លៃទាបដែរឬទេ។

ប្រសិនបើលោកអ្នកដាក់ពាក្យស្នើសុំ ត្រូវប្រាកដថាលោកអ្នកត្រូវបំពេញ ឯកសារភ្ជាប់ B ហើយផ្ញើវាជាមួយនឹងពាក្យស្នើសុំរបស់លោកអ្នក។

13. តើខ្ញុំត្រូវការធានារ៉ាប់រងឥឡូវនេះ ដោយហេតុថា កំណែទម្រង់សុខាភិបាលបានចាប់ផ្តើមឬ?

ចាប់ផ្តើមនៅក្នុងខែមករា ឆ្នាំ2014 មនុស្សភាគច្រើន រួមទាំងកូនក្មេង នឹងត្រូវតម្រូវឲ្យមានការធានារ៉ាប់រងសុខភាព បើពុំដូច្នោះទេ គេត្រូវបង់ការពិន័យពន្ធ។ ការធានារ៉ាប់រងអាចរួមមាន៖ ការធានារ៉ាប់រងតាមរយៈការងារ ការធានារ៉ាប់រងដែលលោកអ្នកទិញដោយខ្លួនឯង, Medicare ឬ Medi-Cal។

ប៉ុន្តែមនុស្សមួយចំនួនរួចកាតព្វកិច្ចក្នុងការទិញធានារ៉ាប់រង។ ប្រជាជនទាំងនោះរួមមាន ប៉ុន្តែមិនកម្រិតត្រឹមតែ សមាជិកនៃក្រុម ឬនិកាយសាសនាដែលទទួលស្គាល់ដោយសហព័ន្ធ ដែលជំនឿសាសនារបស់ពួកគេ ជំទាស់នឹងការទទួលយកអត្ថប្រយោជន៍ពីគម្រោងធានារ៉ាប់រងសុខភាព, អ្នកជាប់ពន្ធធនាគារ, ជនដែលជាសមាជិកកុលសម្ព័ន្ធ, ជនជាតិដើមអាមេរិក ឬជនជាតិដើមអាឡាស្កាដែលទទួលស្គាល់ដោយសហព័ន្ធ, និងជនទាំងឡាយ ដែលត្រូវបង់លើស 8% នៃប្រាក់ចំណូលរបស់ខ្លួនសម្រាប់ការធានារ៉ាប់រងសុខភាពក្រោយពីគិតគូរវិភាគទានរបស់និយោជក ឬជំនួយបុព្វលាភធានារ៉ាប់រង។

ក្នុងឆ្នាំ 2014 ការផាកពិន័យនឹងមានចំនួន 1% នៃប្រាក់ចំណូលប្រចាំឆ្នាំ ឬ ចំនួន $95 ពេលគឺយកចំនួនមួយណាដែលខ្ពស់ជាង។ ការផាកពិន័យនឹងឡើងខ្ពស់រៀងរាល់ឆ្នាំ។ នៅឆ្នាំ 2016 ការផាកពិន័យនឹងមានចំនួន 2.5% នៃប្រាក់ចំណូលប្រចាំឆ្នាំរបស់លោកអ្នក ឬ $695 ពេលគឺយកចំនួនមួយណាដែលខ្ពស់ជាង។ ក្រោយឆ្នាំ 2016 ការផាកពិន័យពន្ធនឹងកើនឡើងរៀងរាល់ ឆ្នាំ ដោយផ្អែកលើការលៃតម្រូវចំណាយក្នុងការរស់នៅ។

សម្រាប់ព័ត៌មានបន្ថែមអំពីការផាកពិន័យ សូមទស្សនាគេហទំព័រ **CoveredCA.com** ឬសូមហៅទូរស័ព្ទទៅកាន់ការិយាល័យផ្តល់សេវាសង្គមនៃខោនធី ឬ Covered California។

14. ខ្ញុំមិនមានព័ត៌មានគ្រប់យ៉ាង ដែលខ្ញុំត្រូវការដើម្បីឆ្លើយសំណួរលើពាក្យ ស្នើសុំទេ។ តើខ្ញុំគួរធ្វើយ៉ាងម៉េច?

ប្រសិនបើលោកអ្នកមិនមានគ្រប់ព័ត៌មានដែលយើងខ្ញុំស្នើសុំទេ សូមចុះហត្ថលេខា រួចផ្ញើពាក្យស្នើសុំរបស់លោកអ្នកមកសិនក៏បាន។ យើងខ្ញុំ នឹងហៅទូរស័ព្ទទៅជម្រាបប្រាប់លោកអ្នកនូវអ្វីដែលត្រូវធ្វើ ក្នុងរយៈពេល 10 ទៅ 15ថ្ងៃតាមប្រតិទិន បន្ទាប់ពីយើងខ្ញុំទទួលបានពាក្យស្នើសុំរបស់លោកអ្នក។ ប្រសិនបើលោកអ្នកមិនបានទទួលដំណឹងអ្វីពីយើងខ្ញុំ សូមទូរស័ព្ទមកយើងខ្ញុំតាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។

15. តើនឹងមានអ្វីកើតឡើងក្រោយពេលខ្ញុំដាក់ពាក្យស្នើសុំ?

យើងខ្ញុំនឹងផ្ញើលិខិតមួយច្បាប់ជូនលោកអ្នកក្នុងរយៈពេល 45ថ្ងៃ ដើម្បីជម្រាបប្រាប់លោកអ្នកអំពីថាតើលោកអ្នក ឬសមាជិកគ្រួសាររបស់លោកគ្រប់លក្ខណៈសម្បត្តិសម្រាប់កម្មវិធីណាមួយ។ ប្រសិនបើលោកអ្នកមិនបានទទួលដំណឹងអ្វីពីយើងខ្ញុំ សូមទូរស័ព្ទមកយើងខ្ញុំតាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។

សំណួរជាទូទៅ *បន្តនៅទំព័របន្ទាប់*

ត្រូវការជំនួយឬ? ទូរស័ព្ទមក Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង ៨ព្រឹកដល់ម៉ោង ៨ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង ៨ព្រឹកដល់ម៉ោង ៦ល្ងាច ឬចូលទៅកាន់ **CoveredCA.com**.

ទទួលជំនួយតាមរយៈ Covered California *(បន្ត)*

16. តើខ្ញុំអាចរកជំនួយក្នុងការដាក់ពាក្យស្នើសុំ ឬក្នុងការជ្រើសរើសគម្រោង បានដែរឬទេ?

ចាស/បាទ! ជំនួយនេះគឺឥតគិតថ្លៃ។ អ្នកផ្តល់ប្រឹក្សាអំពីការចុះឈ្មោះ ដែល មានការទទួលស្គាល់ (Certified Enrollment Counselor) និងភ្នាក់ងារ ធានារ៉ាប់រងដែលមានការទទួលស្គាល់ (Certified Insurance Agent) ក្នុងសហគមន៍ទូទាំងរដ្ឋ ផ្តល់ព័ត៌មានជូនលោកអ្នកអំពីការជ្រើសរើសការ ធានារ៉ាប់រងសុខភាពថ្មីៗ និងជួយជ្រោមជ្រែងដល់ការដាក់ពាក្យស្នើសុំរបស់ លោកអ្នក។ លោកអ្នកក៏អាចរកជំនួយបានផងដែរ តាមរយៈការចូលទៅ កាន់ការិយាល័យផ្តល់សេវាសង្គមនៃខោនធីរបស់លោកអ្នក។ លោកអ្នកអាចទទួលបានជំនួយជាភាសាផ្សេងៗជាច្រើន។

ទទួលជំនួយសម្រាប់ការដាក់ពាក្យស្នើសុំ ឬក្នុងការជ្រើសរើសគម្រោង៖

- **វ៉ែបសាយ**: ចូលទៅកាន់ **CoveredCA.com**។ យើងខ្ញុំមានផ្តល់ជូននូវព័ត៌មានអំពីគម្រោងធានារ៉ាប់រងនីមួយៗ ដែលបានពន្យល់ជាពាក្យពេចន៍ងាយយល់ និងច្បាស់លាស់។
- **តាមទូរស័ព្ទ**: ទូរស័ព្ទមក Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង ៨ព្រឹកដល់ម៉ោង ៨ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង ៨ព្រឹកដល់ម៉ោង ៦ល្ងាច។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ!
- **មកជួបផ្ទាល់**: យើងបានបណ្តុះបណ្តាល អ្នកផ្តល់ប្រឹក្សាអំពីការចុះឈ្មោះ ដែលមានការទទួលស្គាល់ (Certified Enrollment Counselors) និងភ្នាក់ងារ ធានារ៉ាប់រងដែលមានការទទួលស្គាល់ (Certified Insurance Agents) ដែលអាចជួយលោកអ្នកបាន។ ឬលោកអ្នកអាចមកកាន់ការិយាល័យសេវាសង្គម របស់ខោនធីលោកអ្នក។ ជំនួយនេះគឺឥតគិតថ្លៃ! សម្រាប់បញ្ជីទីកន្លែងដែលនៅជិតកន្លែងលោកអ្នករស់នៅ ឬធ្វើការ សូមចូលទៅកាន់ **CoveredCA.com** ឬទូរស័ព្ទមកលេខ **1-800-906-8528** (TTY: 1-888-889-4500)។

17. តើខ្ញុំអាចជ្រើសរើសគម្រោងធានារ៉ាប់រងសុខភាពយ៉ាងដូចម្តេច?

ប្រសិនបើលោកអ្នកគ្រប់លក្ខណៈទទួលគម្រោងធានារ៉ាប់រងសុខភាពឯកជនតាមរយៈ Covered California លោកអ្នកអាចចូលទៅកាន់គេហទំព័រ **CoveredCA.com** ដើម្បីរកទិញដោយងាយ និងប្រៀបធៀបគម្រោងធានារ៉ាប់រងសុខភាព។

Covered California នឹងផ្តល់ជម្រើសអំពីគម្រោង ធានារ៉ាប់រងសុខភាពឯកជន និងគម្រោង Medi-Cal ផងដែរ។ លោកអ្នកអាចជ្រើសរើសកម្រិតនៃការធានារ៉ាប់រងដែលបំពេញបានល្អបំផុតតាមត្រូវការ និងថវិការបស់លោកអ្នក។

- លោកអ្នកអាចជ្រើសរើសបង់តម្លៃប្រចាំខែខ្ពស់ (ហៅថា បុព្វលាភធានារ៉ាប់រង) ដើម្បីលោកអ្នកបង់ចំណាយពីហោប៉ៅខ្លួនឯងតិច នៅពេលលោកអ្នកត្រូវការការថែទាំសុខភាព។
- ***បើពុំដូច្នោះទេ*** លោកអ្នកអាចជ្រើសរើសបង់តម្លៃប្រចាំខែទាប ប៉ុន្តែបង់ចំណាយពីហោប៉ៅខ្លួនឯងច្រើន នៅពេលលោកអ្នកត្រូវការការថែទាំសុខភាព។

ប្រសិនបើលោកអ្នកគ្រប់លក្ខណៈសម្បត្តិទទួល Medi-Cal ការធានារ៉ាប់រងនិងការចំណាយគឺខុសគ្នា ហើយវាអាចនឹងមិនបាច់បង់ក៏បាន។ ដើម្បីសិក្សាបន្ថែមអំពីគម្រោង Medi-Cal នៅក្នុងខោនធីរបស់លោកអ្នក សូមហៅទូរស័ព្ទមកកាន់ Health Care Option តាមរយៈលេខ **1-800-430-4263** (TTY: 1-800-430-7077) ឬ ទស្សនាគេហទំព័រ **www.healthcareoptions.dhcs.ca.gov**។

ជំនួយហិរញ្ញវត្ថុ

18. ខ្ញុំរកលុយមិនបានច្រើនទេ។ តើមានកម្មវិធីអ្វីខ្លះអាចជួយឲ្យខ្ញុំទទួលបានការធានារ៉ាប់រងសុខភាព?

ចាប់ផ្តើមនៅថ្ងៃទី1 ខែមករា ឆ្នាំ2014 អ្នកដែលត្រូវការធានារ៉ាប់រងសុខភាព អាចទទួលបានជំនួយតាមមធ្យោបាយមួយក្នុងចំណោមមធ្យោបាយទាំង នេះ៖

A. ជំនួយជាមួយនឹងបុព្វលាភប្រចាំខ ជំនួយបុព្វលាភអាចជួយឲ្យលោកអ្នកទទួលបានធានារ៉ាប់រងសុខភាពក្នុងតម្លៃសមរម្យ។ អ្នកដែលគ្រប់លក្ខណៈសម្បត្តិទទួលជំនួយបុព្វលាភធានារ៉ាប់រង អាចទទួលជំនួយជាមុនបាន (មុនពេលពួកគេដាក់ប្រតិវេទន៍ពន្ធ) ដើម្បីធ្វើឲ្យបុព្វលាភធានារ៉ាប់រងប្រចាំខែរបស់ខ្លួនកាន់តែទាប។ ឬពួកគេអាចទទួលជំនួយនេះបាននៅចុងឆ្នាំ ហើយបង់ពន្ធតិច។

  បរិមាណជំនួយសម្រាប់បុព្វលាភប្រចាំខែ អាស្រ័យលើទំហំគ្រួសារ និងប្រាក់ចំណូលគ្រួសាររបស់លោកអ្នក។

B. Medi-Cal: Medi-Cal គឺជាកម្មវិធី Medicaid នៃរដ្ឋកាលីហ្វ័រញ៉ាដែលត្រូវ បានបង់ជាមួយនឹងពន្ធរបស់រដ្ឋ និងសហព័ន្ធ។ វាជាការធានារ៉ាប់រងសុខភាពសម្រាប់ប្រជាជននៃរដ្ឋកាលីហ្វ័រញ៉ា ដែលមានប្រាក់ចំណូលទាប និងបំពេញ តាមលក្ខខណ្ឌតម្រូវដាក់លាក់មួយចំនួន។

  ប្រសិនប្រាក់ចំណូលបិតនៅក្នុងកម្រិតកំណត់នៃ Medi-Cal សម្រាប់ទំហំគ្រួសាររបស់លោកអ្នកនោះ លោកអ្នកនឹងទទួលបានការធានារ៉ាប់រងពី Medi-Cal ដោយឥតគិតថ្លៃ។

19. ប្រសិនបើប្រាក់ចំណូលរបស់ខ្ញុំមានការផ្លាស់ប្តូរ តើជំនួយបុព្វលាភធានារ៉ាប់រងរបស់ខ្ញុំនឹងមានការផ្លាស់ប្តូរភ្លាមៗឬទេ?

ទេ ជំនួយបុព្វលាភធានារ៉ាប់រងរបស់លោកអ្នកនឹងមិនមានការផ្លាស់ប្តូរភ្លាមៗទេ។ យើងខ្ញុំនឹងដំណើរការព័ត៌មានថ្មីណាមួយ ដែលយើងខ្ញុំមាន។ ហើយយើងខ្ញុំនឹងជម្រាបលោកអ្នក ប្រសិនបើបរិមាណបុព្វលាភធានារ៉ាប់រងរបស់លោកអ្នកមានការផ្លាស់ប្តូរ។

20. ប្រសិនបើប្រាក់ចំណូលរបស់ខ្ញុំមានការផ្លាស់ប្តូរ តើការផ្លាស់ប្តូរនោះនឹង ប៉ះពាល់ដល់រូបខ្ញុំនៅពេលខ្ញុំធ្វើប្រវេទ៍ន៍ពន្ធរបស់ខ្ញុំយ៉ាងដូចម្តេច?

សំខាន់ត្រូវរាយការណ៍ប្រាប់ Covered California អំពីការផ្លាស់ប្តូរប្រាក់ចំណូលដែលធ្វើឲ្យប៉ះពាល់ដល់បរិមាណជំនួយបុព្វលាភធានារ៉ាប់រងដែលលោកអ្នកទទួល។ ប្រសិនបើប្រាក់ចំណូលរបស់លោកអ្នកថយចុះ លោកអ្នកអាចគ្រប់លក្ខណៈសម្បត្តិទទួលបរិមាណជំនួយបុព្វលាភធានារ៉ាប់រងកាន់តែខ្ពស់ ហើយបន្ថយការចំណាយលុយហោប៉ៅរបស់លោកអ្នក បានកាន់តែច្រើន។ ប៉ុន្តែទោះជាយ៉ាងណា ប្រសិនបើប្រាក់ចំណូលរបស់លោកអ្នកកើនឡើង លោកអ្នកអាចទទួលជំនួយបុព្វលាភធានារ៉ាប់រងច្រើនពេក ហើយគេអាចតម្រូវឲ្យលោកអ្នកបង់សងប្រាក់នោះនៅពេលលោកអ្នក ធ្វើប្រតិវេទន៍ពន្ធរបស់លោកអ្នកសម្រាប់ឆ្នាំអត្ថប្រយោជន៍។

***សំណួរជាទូទៅ** បន្តនៅទំព័របន្ទាប់*

ត្រូវការជំនួយឬ? ទូរស័ព្ទមក Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង ៨ព្រឹកដល់ម៉ោង ៨ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង ៨ព្រឹកដល់ម៉ោង ៦ល្ងាច ឬចូលទៅកាន់ **CoveredCA.com**.

ជំនួយហិរញ្ញវត្ថុ *(បន្ត)*

21. តើធ្វើដូចម្តេចបើខ្ញុំមិនបានដាក់ប្រវេទន៍ពន្ធឆ្នាំមុន?

ប្រសិនបើលោកអ្នកមិនបានដាក់ប្រវេទន៍ពន្ធឆ្នាំមុន លោកអ្នកនៅតែអាចដាក់ពាក្យស្នើសុំការធានារ៉ាប់រងសុខភាព និងទទួលជំនួយបុព្វលាភធានារ៉ាប់រងនេះបាន។ យើងនឹងប្រើប្រាស់ប្រាក់ចំណូលរបស់លោកអ្នក ដើម្បីជួយយើងខ្ញុំក្នុងការកត់ការធានារ៉ាប់រងសុខភាពដែលសមស្របបំផុតសម្រាប់លោកអ្នក និងក្រុមគ្រួសាររបស់លោកអ្នក។

ប្រសិនបើលោកអ្នកគ្រប់លក្ខណៈសម្បត្តិទទួលជំនួយបុព្វលាភធានារ៉ាប់រង លោកអ្នកត្រូវតែដាក់ប្រវេទន៍ពន្ធសម្រាប់ឆ្នាំអត្ថប្រយោជន៍។

22. តើធ្វើដូចម្តេចប្រសិនបើប្រាក់ចំណូលខ្ញុំផ្លាស់ប្តូរក្រោយពេលខ្ញុំដាក់ពាក្យស្នើសុំ?

ប្រសិនបើប្រាក់ចំណូលលោកអ្នកផ្លាស់ប្តូរ វាអាចធ្វើឲ្យផ្លាស់ប្តូរដល់ប្រភេទនៃការធានារ៉ាប់រងសុខភាពដែលលោកអ្នកគ្រប់លក្ខណៈសម្បត្តិទទួល។

ប្រសិនបើលោកអ្នកមានការធានារ៉ាប់រងសុខភាពឯកជនតាមរយៈ Covered California សូមហៅទូរស័ព្ទរាយការណ៍អំពីការផ្លាស់ប្តូរប្រាក់ ចំណូលរបស់លោកអ្នក ដែលអាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិទទួលបានរបស់លោកអ្នកក្នុងរយៈពេល 30ថ្ងៃ។

ប្រសិនបើលោកអ្នកមាន Medi-Cal ហើយប្រាក់ចំណូលរបស់លោកអ្នកមានការផ្លាស់ប្តូរ សូមទំនាក់ទំនងការិយាល័យសេវាសង្គមកិច្ចនៃខោនធីរបស់លោកអ្នក ក្នុងរយៈពេល10ថ្ងៃ។

សំណួរផ្សេងៗទៀត

23. តើអ្នកគ្រប់គ្នានៅក្នុងពាក្យស្នើសុំត្រូវតែជាពលរដ្ឋអាមេរិក ឬប្រជាជាតិអាមេរិកឬ?

ទេ លោកអ្នកអាចគ្រប់លក្ខណៈសម្បត្តិទទួលការធានារ៉ាប់រងសុខភាពតាមរយៈ Medi-Cal បាន ទោះបីលោកអ្នកមិនមែនជាពលរដ្ឋអាមេរិក ឬប្រជាជាតិអាមេរិកក៏ដោយ។

24. តើគ្រួសារខ្ញុំ និងខ្ញុំគ្រប់លក្ខណៈសម្បត្តិទទួលបានកម្មវិធីដូចគ្នាទេ?

អាស្រ័យលើទំហំគ្រួសារ ឬប្រាក់ចំណូលគ្រួសាររបស់លោកអ្នក លោកអ្នក ឬគ្រួសារលោកអ្នកអាចគ្រប់លក្ខណៈសម្បត្តិទទួលបានកម្មវិធីខុសៗគ្នា។ ជាឧទាហរណ៍ លោកអ្នកអាចគ្រប់លក្ខណៈសម្បត្តិទទួលបានការធានារ៉ាប់រងសុខភាពឯកជនដែលមាន តាមរយៈ Covered California។ ប៉ុន្តែកូនរបស់លោកអ្នកអាចគ្រប់លក្ខណៈសម្បត្តិទទួល Medi-Cal ដោយឥតគិត ថ្លៃ។ យើងខ្ញុំនឹងជម្រាបជូនលោកអ្នកថាតើលោកអ្នក ឬសមាជិកដទៃទៀតគ្រប់លក្ខណៈសម្បត្តិទទួលការធានារ៉ាប់រងសុខភាពណាមួយ។

25. ពាក្យស្នើសុំនេះទាមទារនូវព័ត៌មានផ្ទាល់ខ្លួនជាច្រើន។ តើ Covered California នឹងចែករំលែកព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានផ្ទាល់ខ្លួនរបស់ខ្ញុំឬ?

ទេ ព័ត៌មានដែលលោកអ្នកផ្តល់គឺជាព័ត៌មានសម្ងាត់ និងមានការធានាតាមការតម្រូវដោយច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ។ យើងខ្ញុំនឹងប្រើប្រាស់ព័ត៌មានរបស់លោកអ្នកត្រឹមតែមើលថាតើលោកអ្នកគ្រប់លក្ខណៈសម្បត្តិក្នុងការទទួលបានការធានារ៉ាប់រងសុខភាពដែរឬទេ។

26. តើខ្ញុំនឹងអាចប្រើប្រាស់គម្រោងធានារ៉ាប់រងសុខភាព Covered California ថ្មីរបស់ខ្ញុំភ្លាមដែរឬទេ?

ប្រសិនបើលោកអ្នកដាក់ពាក្យស្នើសុំរវាងខែតុលា និងខែធ្នូ ឆ្នាំ2013 គម្រោងសុខភាពចាប់ផ្តើមផ្តល់សេវានៅថ្ងៃទី1 ខែមករា ឆ្នាំ2014។ ប្រសិនបើលោកអ្នកដាក់ពាក្យស្នើសុំនៅក្រោយថ្ងៃទី1 ខែមករា ឆ្នាំ2014 គម្រោងសុខភាពរបស់លោកអ្នក អាចចាប់ផ្តើមផ្តល់សេវាភ្លាមៗនៅបន្ទាប់ពីខែដែលលោកអ្នកដាក់ពាក្យស្នើសុំ។

27. តើលោកអ្នកចង់មានន័យថាម៉េចចំពោះពាក្យថា "ពិការភាព"?

លោកអ្នកអាចមានពិការភាព និងគ្រប់លក្ខណៈសម្បត្តិទទួល Medi-Cal ប្រសិនបើ:

- លោកអ្នកគរថ្លង់ ឬមានការបាត់បង់ល្បឿនធ្ងន់ធ្ងរ។
- លោកអ្នកពិការភ្នែក ឬបាត់បង់គំហើញធ្ងន់ធ្ងរ ទោះបីពេលពាក់វ៉ែនតា។
- លោកអ្នកមានពិការភាពផ្នែកបញ្ញា ឬការយល់ដឹង និងមានពិបាកចងចាំ ផ្តោតអារម្មណ៍ ឬធ្វើការសម្រេចចិត្ត។
- លោកអ្នកមានបញ្ហាមិនអាចដើរបាន និងពិបាកដើរ ឬឡើងជណ្តើរ។
- លោកអ្នកមានការពិបាកងូតទឹក ឬស្លៀកពាក់ ឬធ្វើសកម្មភាពប្រចាំថ្ងៃស្រដៀងគ្នា។
- លោកអ្នកមានស្ថានភាពកាយ ចិត្ត ឬអារម្មណ៍ និងមានការពិបាកក្នុងការធ្វើអ្វីមួយ (ដូចជា ដើរទិញតាវ៉ាន់ ឬទៅជួបវេជ្ជបណ្ឌិត) ដោយគ្មានជំនួយ។

លោកអ្នកមិនត្រូវតែទទួលសេវាជំនួយពិសេសនៅក្នុងផ្ទះ ឬរស់នៅក្នុងប្រភេទណាមួយនៃកន្លែងថែទាំ ឬកន្លែងរស់ណាមួយដោយមានជំនួយនោះទេ។

28. ខ្ញុំមានស្ថានភាព ឬពិការភាពកាលពីមុន។ តើខ្ញុំអាចទទួលការធានារ៉ាប់រងសុខភាព តាមរយៈ Covered California ហានទេ?

បាន លោកអ្នកអាចទទួលការធានារ៉ាប់រងសុខភាព ដោយមិនគិតអំពីស្ថានភាពសុខភាពបច្ចុប្បន្ន ឬអតីត ឬពិការភាពបច្ចុប្បន្ន ឬកាលពីមុនឡើយ។

ចាប់ផ្តើមនៅក្នុងឆ្នាំ 2014 គម្រោងធានារ៉ាប់រងសុខភាពភាគច្រើន មិនអាចបដិសេធផ្តល់ការធានារ៉ាប់រងចំពោះលោកអ្នក ឬមិនអាចគិតលុយលោកអ្នកច្រើន ដោយសារលោកអ្នកមានស្ថានភាពសុខភាព ឬពិការភាពពីមុនឡើយ។

29. ខ្ញុំទើបតែដឹងថាខ្ញុំមានផ្ទៃពោះ។ តើខ្ញុំអាចដាក់ពាក្យស្នើសុំការធានារ៉ាប់រងសុខភាព ដែលនឹងធានារ៉ាប់រងខ្ញុំក្នុងអំឡុងពេលខ្ញុំមានផ្ទៃពោះបានទេ?

ចាស/បាទ។ ត្រូវប្រាកដក្នុងការឆ្លើយ ចាស/បាទ ទៅនឹងសំណួរនៃពាក្យស្នើសុំ "តើលោកអ្នកមានផ្ទៃពោះឬ?" ឬចូរប្រាប់អ្នកដែលជួយបំពេញពាក្យស្នើសុំរបស់លោកអ្នក។ លោកអ្នកអាចដាក់ពាក្យស្នើសុំការធានារ៉ាប់រងសុខភាពដែលអាចធានារ៉ាប់រងលើការថែទាំមុនពេលសម្រាលកូន កំពុងសម្រាល និងការថែទាំក្រោយពេលសម្រាល។ គម្រោងធានារ៉ាប់រងសុខភាពលែងអាចបដិសេធលោកអ្នកក្នុងការទទួលការធានារ៉ាប់រងសុខភាពទៀតឡើយ ប្រសិនបើលោកអ្នកមានផ្ទៃពោះ។

***សំណួរជាទូទៅ** បន្តនៅទំព័របន្ទាប់*

ត្រូវការជំនួយឬ? ទូរស័ព្ទមក Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង 8ព្រឹកដល់ម៉ោង 8ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង 8ព្រឹកដល់ម៉ោង 6ល្ងាច ឬចូលទៅកាន់ **CoveredCA.com**.

សំណួរផ្សេងៗទៀត *(បន្ត)*

30. ទើបតែមានកូនង៉ែតថ្មីម្នាក់។ តើខ្ញុំគួរធ្វើដូចម្តេចអំពីការធានារ៉ាប់រងសុខភាព?

ប្រសិនបើលោកអ្នកមិនមាន Medi-Cal ឬ Access for Infants and Mother (ការទទួលបានការធានារ៉ាប់រងសម្រាប់កូននិងម្តាយ AIM) នៅពេលកំពុងសម្រាលកូន ចូរបំពេញពាក្យស្នើសុំនេះ សម្រាប់កូនទើបនឹងកើតរបស់លោកអ្នក។

ប្រសិនបើលោកអ្នកពិតជាមាន Medi-Cal ឬ AIM ក្នុងអំឡុងពេលលោកអ្នកមានផ្ទៃពោះ លោកអ្នកមិនចាំបាច់បំពេញពាក្យ ស្នើសុំនេះទេ។

- រួមបញ្ចូលព័ត៌មានម្តាយលើទំព័រទី2 នៃពាក្យស្នើសុំនេះ
- ប្រសិនបើលោកអ្នកមាន Medi-Cal ចូរហៅទូរស័ព្ទទៅកាន់ការិយាល័យសេវាសង្គមនៃខោនធីរបស់លោកអ្នក ដើម្បីឲ្យប្រាកដថាកូនង៉ែតរបស់អ្នកបានទទួលការធានារ៉ាប់រងចាប់ពីពេលកើត ឬចូរបំពេញទម្រង់ពាក្យស្នើសុំទាក់ទងនឹងកូនទើបកើត។ ចូរព្រីនទម្រង់បែបបទនេះចេញពីគេហទំព័រ **www.dhcs.ca.gov/formsandpubs/forms/Forms/ mc330.pdf**។
- ប្រសិនបើលោកអ្នកមាន AIM ចូរហៅទូរស័ព្ទមកកាន់លេខ **1-800-433-2611** ឬចូលទៅកាន់ **aim.ca.gov** ដើម្បីចុះឈ្មោះកូនង៉ែតរបស់អ្នក។

31. តើខ្ញុំនឹងគ្រប់លក្ខណៈសម្បត្តិទទួលការធានារ៉ាប់រងទេ ប្រសិនបើខ្ញុំមិនមែនជាពលរដ្ឋម្នាក់ ឬមិនមានឋានភាពអន្តោប្រវេសន៍ដែលបំពេញគ្រប់លក្ខខណ្ឌតម្រូវទេនោះ?

អ្នកដែលរស់នៅរដ្ឋកាលីហ្វ័រញ៉ា អាចដាក់ពាក្យស្នើសុំការធានារ៉ាប់រងសុខភាពនេះបាន ដោយប្រើប្រាស់ពាក្យស្នើសុំនេះ។ មានតែអ្នកដែលដាក់ពាក្យស្នើសុំនេះប៉ុណ្ណោះ ត្រូវផ្តល់លេខសន្តិសុខសង្គម ឬព័ត៌មានស្តីអំពីឋានភាពអន្តោប្រវេសន៍។

ប៉ុន្តែលោកអ្នកអាចគ្រប់លក្ខណៈសម្បត្តិទទួលកម្មវិធីធានារ៉ាប់រងសុខភាពមួយចំនួន ដោយមិនគិតអំពីឋានភាពអន្តោប្រវេសន៍របស់លោកអ្នក និងទោះបីជាលោកអ្នកមិនមានលេខសន្តិសុខសង្គមក៏ដោយ។

យើងខ្ញុំនឹងរក្សាព័ត៌មានរបស់លោកអ្នកជាការសម្ងាត់ ហើយចែករំលែកព័ត៌មាននេះជាមួយទីភ្នាក់ងាររដ្ឋាភិបាលដទៃទៀត ដើម្បីពិនិត្យមើលកម្មវិធី ណាមួយដែលលោកអ្នកគ្រប់លក្ខណៈសម្បត្តិទទួលប៉ុណ្ណោះ។

32. តើលោកអ្នកបិតក្នុងការថែទាំជាកូនចិញ្ចឹមនៅខួបកំណើតអាយុ 18ឆ្នាំឬ?

ប្រសិនបើលោកអ្នកបិតនៅក្នុងការថែទាំជាកូនចិញ្ចឹម ហើយបានទទួល Medicaid នៅរដ្ឋណាមួយ នៅពេលលោកអ្នកដល់អាយុ 18ឆ្នាំ ហើយឥឡូវនេះ លោកអ្នកមានអាយុរវាងពី 18ឆ្នាំ និង 26ឆ្នាំ លោកអ្នកអាចគ្រប់លក្ខណៈសម្បត្តិទទួល Medi-Cal។ បន្ទាប់មកយើងនឹងបញ្ជាក់ថាលោកអ្នកគឺជាអ្នកស្រុករស់ នៅរដ្ឋកាលីហ្វ័រញ៉ា យើងនឹងចុះឈ្មោះលោកអ្នកក្នុង Medi-Cal ដោយឥតគិត ថ្លៃ។ បន្ទាប់មកយើងខ្ញុំនឹងបញ្ជាក់ថា លោកអ្នកបានបិតនៅក្នុងការថែទាំជាកូនចិញ្ចឹម និងមាន Medicaid ពីមុនមក។

33. អ្វីទៅជាការចាត់ទុកថាជាការបើកប្រាក់តែមួយលើក?

ការបើកប្រាក់តែមួយលើក ត្រូវបានអនុញ្ញាតសម្រាប់តែប្រាក់ឈ្នួលល្បែង, ប្រាក់ង្វាន់, ការលុបបំណុលចោល, ប្រាក់ខែ ឬប្រាក់ឈ្នួលពីនិយោជកមុនដែលទទួលបានដោយប្តី/ប្រពន្ធដែលនៅរស់, ប្រាក់សន្តិសុខសង្គមប្រតិសកម្ម និងប្រាកអត្ថប្រយោជន៍នៃការចូលនិវត្តន៍របស់កម្មករធ្វើការនៅតាមផ្លូវដែក, ប្រាក់ឈ្នះឆ្នោត, អំណោយ, និងអត្ថប្រយោជន៍នៃការធានារ៉ាប់រងប្រតិសកម្ម សម្រាប់អ្នកអត់ការងារធ្វើ។

34. តើពាក្យថា "បម្រើការងារឲ្យខ្លួនឯង" មានន័យដូចម្តេច?

អ្នកដែលបម្រើការឲ្យខ្លួន រកចំណូលចិញ្ចឹមជីវិតដោយផ្អាល់ពីអាជីវកម្ម ឬ សេវាផ្ទាល់ខ្លួន។ ពួកគេមិនទទួលលុយពីក្រុមហ៊ុនណាមួយដែលបើកលុយឲ្យពួកគេទេ។

35. តើខ្ញុំអាចទទួលព័ត៌មានអំពីការក្លាយជាអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោត នៅឯណា?

ប្រសិនបើលោកអ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតនៅកន្លែង ដែលលោកអ្នករស់នៅបច្ចុប្បន្នទេ ហើយមានបំណងចង់ដាក់ពាក្យចុះឈ្មោះដើម្បីបោះឆ្នោតថ្ងៃនេះ សូមចូលទៅកាន់គេហទំព័រ **registertovote.ca.gov** ។ ឬ សូមទូរស័ព្ទមកលេខ **1-800-345-VOTE (8683)**។

36. ខ្ញុំជាជនជាតិដើមអាមេរិក ឬជនជាតិដើមអាឡាស្កា។ តើ Covered California អាចជួយខ្ញុំបានយ៉ាងដូចម្តេច?

ប្រសិនបើលោកអ្នកត្រូវបានទទួលស្គាល់ដោយរដ្ឋសហព័ន្ធជាជនជាតិដើមអាមេរិក ឬជនជាតិដើមអាឡាស្កា ឬប្រសិនបើលោកអ្នកគ្រប់លក្ខណៈសម្បត្តិតាមវិធីមួយផ្សេងទៀតដើម្បីទទួលសេវាពីសេវាសុខភាពឥណ្ឌាក្រហម កម្មវិធីសុខភាពកុលសម្ព័ន្ធ ឬកម្មវិធីសុខភាពឥណ្ឌាក្រហមនៅទីក្រុងនោះ លោកអ្នកអាចគ្រប់លក្ខណៈសម្បត្តិទទួល Medi-Cal ដោយឥតគិតថ្លៃ ឬតម្លៃទាប ដូចជាជំនួយក្នុងការបង់បុព្វលាភធានារ៉ាប់រង ឬ គ្មានការបង់រួម។ លោកអ្នកក៏អាចមានពេលវេលាពិសេសក្នុងការចុះឈ្មោះប្រចាំខែផងដែរ។

- ចូរបំពេញឯកសារភ្ជាប់ A ហើយធ្វើដោយមានកំស្តុតាងបញ្ជាក់ថាលោកអ្នកគឺជាជនជាតិដើមឥណ្ឌា ឬជនជាតិដើមអាឡាស្កា។ លោកអ្នកអាចប្រើប្រាស់កាតចុះឈ្មោះកុលសម្ព័ន្ធ ឬលិខិតបញ្ជាក់អំពីសញ្ញាបត្រឈាមឥណ្ឌាក្រហម (Certificate of Degree of Indian Blood, CDIB) ពីការិយាល័យកិច្ចការឥណ្ឌាក្រហម (Bureau of Indian Affairs)។
- ប្រសិនបើលោកអ្នកគ្រប់លក្ខណៈសម្បត្តិទទួល Medi-Cal លោកអ្នកមិនចាំបាច់ផ្ញើកំស្តុតាងបញ្ជាក់អំពីជនជាតិដើមអាមេរិក ឬជនជាតិដើមអាឡាស្កាទេ។ ដើម្បីពិនិត្យមើលថាតើលោកអ្នកគ្រប់លក្ខណៈសម្បត្តិទទួល Medi-Cal ចូរមើលឯកសារភ្ជាប់ F។

37. តើធ្វើដូចម្តេចបើខ្ញុំមិនយល់ព្រមទៅនឹងការសម្រេច ដែល Covered California ធ្វើឡើង?

លោកអ្នកអាចដាក់បណ្តឹងតវ៉ាមិនសុខចិត្ត។ ដើម្បីប្តឹងតវ៉ាមិនសុខចិត្ត ចំពោះសេចក្តីសម្រេចនោះ សូមទាក់ទង Covered California តាមមធ្យោបាយមួយក្នុងចំណោមធ្យោបាយទាំងនេះ៖

- **តាមវិបសាយ**: ចូលទៅកាន់ **CoveredCA.com**។
- **តាមទូរស័ព្ទ**: ទូរស័ព្ទមក Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង ៨ព្រឹកដល់ម៉ោង ៨ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង ៨ព្រឹកដល់ម៉ោង ៦ល្ងាច។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ!
- **តាមទូរសារ**: ផ្ញើពាក្យបណ្តឹងតវ៉ារបស់លោកអ្នកតាមទូរសារលេខ **1-888-329-3700**។
- **តាមរយៈសំបុត្រ**: ផ្ញើពាក្យសុំរបស់ Covered California តាមរយៈសំបុត្រមកកាន់
  Covered California
  P.O. Box 989725
  West Sacramento, CA 95798-9725
- **មកជួបផ្ទាល់**: យើងបានបណ្តុះបណ្តាល អ្នកផ្តល់ប្រឹក្សាអំពីការចុះឈ្មោះដែលមានការទទួលស្គាល់ (Certified Enrollment Counselors) និង ភ្នាក់ងារ ធានារ៉ាប់រងដែលមានការទទួលស្គាល់ (Certified Insurance Agents) ដែលអាចជួយលោកអ្នកបាន។ ឬលោកអ្នកអាចមកកាន់ការិយាល័យសេវា សង្គមរបស់ខោនធីលោកអ្នក។ ជំនួយនេះគឺឥតគិតថ្លៃ!

  សម្រាប់បញ្ជីឈ្មោះ អ្នកផ្តល់ប្រឹក្សាអំពីការចុះឈ្មោះដែលមានការទទួលស្គាល់ និងភ្នាក់ងារធានារ៉ាប់រងដែលមានការទទួលស្គាល់ នៅក្បែរកន្លែងលោកអ្នករស់នៅ ឬធ្វើការ ឬបញ្ជីឈ្មោះការិយាល័យផ្តល់សេវាសង្គមរបស់ខោនធីដែលបិតនៅក្បែរលោកអ្នក សូមអញ្ជើញចូលទៅកាន់គេហទំព័រ **CoveredCA.com** ឬទូរស័ព្ទមកលេខ **1-800-906-8528** (TTY: 1-888-889-4500)។

ត្រូវការជំនួយឬ? ទូរស័ព្ទមក Covered California តាមរយៈលេខ **1-800-906-8528** (TTY: 1-888-889-4500)។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃ។ លោកអ្នកអាចទូរស័ព្ទមក ពីថ្ងៃចន្ទដល់សុក្រ ពីម៉ោង ៨ព្រឹកដល់ម៉ោង ៨ល្ងាច និងថ្ងៃសៅរ៍ពីម៉ោង ៨ព្រឹកដល់ម៉ោង ៦ល្ងាច ឬចូលទៅកាន់ **CoveredCA.com**.

អាចមានជំនួយបន្ថែម

CalFresh

តើលោកអ្នកត្រូវការជំនួយក្នុងការទិញម្ហូបអាហារ សម្រាប់លោកអ្នក និង ក្រុមគ្រួសាររបស់លោកអ្នកទេ?

CalFresh អាចជួយលោកអ្នកបាន! នៅរដ្ឋកាលីហ្វ័រញ៉ា កម្មវិធីជំនួយ អាហារូបត្ថម្ភបន្ថែមនៃរដ្ឋសហព័ន្ធ (SNAP) ត្រូវបានគេស្គាល់ថាជា CalFresh។ CalFresh ជួយលោកអ្នកក្នុងការបង់លុយទិញបន្លែ ផ្លែឈើ និងអាហារសុខភាពផ្សេងទៀត។

ដើម្បីពិនិត្យថាតើលោកអ្នកគ្រប់លក្ខណៈសម្បត្តិទទួល CalFresh សូម ហៅទូរស័ព្ទមកកាន់លេខ **1-877-847-3663** ឬចូលទៅកាន់ **www.calfresh.ca.gov** ឬដាក់ពាក្យតាមគេហទំព័រ **benefitscal.org**។

Welltopia តាមរយៈ DHCS

ចូលទស្សនា Welltopia តាមរយៈនាយកដ្ឋានសេវាថែទាំសុខភាព (DHCS) ទីកន្លែងថែទាំសុខភាព នៅលើ Facebook និង Twitter! លោកអ្នកនឹងរកឃើញការណែនាំសំខាន់អំពីការបន្ថយស្ត្រេស ទទួលទានអាហារកាន់តែមានសុខភាព រីករាយនឹងសកម្មភាពលំហាត់ប្រាណ ឈប់ជក់បារី និងច្រើនទៀត។

Welltopia តាមរយៈ DHCS មាន:

- កម្មវិធីសុខភាពប្រកបដោយភាពរីករាយ ដោយឥតគិតថ្លៃ
- វីដេអូរីករាយចាប់អារម្មណ៍
- តំណភ្ជាប់ទៅកាន់:
  - រូបមន្តធ្វើម្ហូបងាយៗ និងមានរសជាតិឆ្ងាយ
  - ទីតាំងផ្សារកសិករ
  - CalFresh
- ទីកន្លែងនិងសកម្មភាពសប្បាយៗសម្រាប់លោកអ្នក និងកូនលោកអ្នក
- ការអប់រំ និងការធ្វើតេស្តរកការងារធ្វើ និងសេវាផ្សេងទៀតធ្វើឲ្យជីវិតលោកអ្នកកាន់តែមានភាពងាយស្រួលបន្តិចទៀត។

ចុច "Like" Welltopia by DHCS នៅលើ Facebook!
ចូលទៅកាន់: Facebook.com/DHCSWelltopia

ចូលរួមជាមួយយើងខ្ញុំ! @Weltopiadhcs

Earned Income Tax Credit (EITC)

EITC គឺជាអត្ថប្រយោជន៍សម្រាប់អ្នកធ្វើការ ដែលមានប្រាក់ចំណូលទាប ទៅមធ្យម។ ពន្ធប្រភេទនេះបន្ថយបរិមាណពន្ធដែលលោកអ្នកជំពាក់
ហើយក៏អាចឲ្យលោកអ្នកសងវិញបានដែរ។

www.eitc.ca.gov

Child Tax Credit

ឥណទានពន្ធនេះអាចមានតម្លៃច្រើនដល់ $1,000 ក្នុងក្មេងម្នាក់ដែលគ្រប់លក្ខណៈសម្បត្តិ អាស្រ័យលើប្រាក់ចំណូលរបស់លោកអ្នក។

www.childtaxcredit.ca.gov

ទទួលបានជំនួយជាភាសាផ្សេងៗទៀត

លោកអ្នកអាចទទួលបានជំនួយក្នុងការដាក់ពាក្យស្នើសុំនេះជាភាសាផ្សេងៗទៀត។ សូមទូរស័ព្ទមកលេខ 1-800-906-8528.

Podemos ayudarle en español a llenar esta solicitud. Llame al 1-800-300-0213.

SPANISH

您可以透過其他語言獲得此申請的幫助。請致電 1-800-300-1533.

TRADITIONAL CHINESE

Quý vị có thể được trợ giúp về đơn đăng ký này bằng tiếng Việt. Hãy gọi 1-800-652-9528.

VIETNAMESE

이 응용 프로그램에 대한 한국어 지원을 받으실 수 있습니다. 전화: 1-800-738-9116.

KOREAN

Maaari kang kumuha ng tulong para sa aplikasyong ito sa Tagalog. Tumawag sa 1-800-983-8816.

TAGALOG

Koj txais tau kev pab nrog kev tso npe no ua lus Hmoob. Hu 1-800-771-2156.

HMONG

Вы можете получить помощь в оформлении этой заявки на русском языке. Звоните по телефону 1-800-778-7695.

RUSSIAN

Դուք կարող եք հայերենով օգնություն ստանալ այս դիմումի ձևը լրացնելու հարցում: Զանգահարեք 1-800-996-1009.

ARMENIAN

می توانید در ارتباط با این فرم تقاضا به زبان های دیگر کمک دریافت کنید. با شماره 1-800-921-8879 تماس بگیرید.

FARSI

អ្នកអាចទទួលបានជំនួយចំពោះពាក្យសុំនេះជាភាសាខ្មែរ។ សូមទូរស័ព្ទមកលេខ 1-800-906-8528.

KHMER

يمكنك الحصول على مساعدة خاصة بهذا التطبيق باللغة العربية. اتصل بـ 1-800-826-6317.

ARABIC

ចុច "Like" Covered California នៅលើ Facebook!
ចូលទៅកាន់: Facebook.com/CoveredCA

ចូលរួមជាមួយយើងខ្ញុំ! @CoveredCA